# ៩. សម្លឹងមើលទៅអនាគត

ការអភិវឌ្ឍន៍យុទ្ធសាស្ត្រអប់រំជាតិទទួលឥទ្ធិពលយ៉ាងខ្លាំងពីកត្តាជាច្រើន។ ភាពស្មុគស្មាញខាងហិរញ្ញវត្ថុជាអ្នកកំណត់ថា តើរដ្ឋាភិបាលត្រូវផ្តល់ការអប់រំតាមសាលារដ្ឋ ឬសាលាឯកជន។ នេះគឺជាជំរើសដែលរដ្ឋាភិបាលនានាកំពុងជួបប្រទះនៅបច្ចុប្បន្ន។ លក្ខណៈវិនិច្ឆ័យសិទ្ធិមនុស្សគួរតែជាចំណែកមួយនៃការសំរេចចិត្តបែបនេះ (ទោះបីជាគេមិនដែលធ្វើក៏ដោយ) ជាពិសេសនៅកន្លែងច្បាប់សិទ្ធិមនុស្សអន្តរជាតិបញ្ជាក់ច្បាស់អំពីកាតព្វកិច្ចរបស់រដ្ឋាភិបាល ដូចជា ត្រូវធានាផ្តល់ការអប់រំដោយកាតព្វកិច្ច និងដោយមិនគិតថ្លៃសំរាប់កុមារទាំងអស់គ្នា ឬលុបបំបាត់ការរើសអើងយេនឌ័រនៅក្នុង និងតាមរយៈការអប់រំ។

រដ្ឋាភិបាលនៅគ្រប់ប្រទេសទាំងអស់ត្រូវសំរេចរើសយករវាងចំនួនច្រើនលើសលុបនៃអាទិភាពគោលនយោបាយ ពោលគឺកំរិតនៃការវិនិយោគរដ្ឋនៅក្នុងការអប់រំ នៅក្នុងខណៈដែលគេកំពុងជួបប្រទះបញ្ហាថវិកា។ សំរាប់ប្រទេសដែលកំពុងអភិវឌ្ឍន៍ ការសំរេចចិត្តបែបនេះមានលក្ខណៈកាន់តែស្មុគស្មាញ និងសារៈសំខាន់ពីព្រោះថាតម្រូវការហាក់ដូចជាធំធេងជាងធនធានដែលមានច្រើនណាស់។ ដើម្បីអនុវត្តការអប់រំផ្អែកលើសិទ្ធិទាមទារ (១) ចំណេះដឹងនៃសិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបញ្ចូលក្នុងយុទ្ធសាស្ត្រអប់រំ (២) ការអភិវឌ្ឍជំនាញចាំបាច់ដើម្បីកែប្រែសិទ្ធិមនុស្សទាំងនេះឲ្យសមស្របតាមស្ថានភាពរបស់ប្រទេសជាតិ។ គោលបំណងនៃឯកសារនេះគឺដើម្បីផ្តល់ជាធនធានសំរាប់គោលដៅនេះ។

ឯកសារនេះមិនទាមទារថាបានដោះស្រាយបញ្ហាសំខាន់ៗ ឬថាបានផ្តល់ជាយុទ្ធវិធីសកលសំរាប់ដោះស្រាយបញ្ហាស្មុគស្មាញនោះទេ។ ផ្ទុយទៅវិញ ឯកសារនេះបានលើកឡើងពីស្តង់ដាសិទ្ធិមនុស្សសកលដែលមាននៅក្នុងច្បាប់អន្តរជាតិ ដែលកំណត់កាតព្វកិច្ចរបស់រដ្ឋាភិបាល និងដាក់រយៈពេលកំហិតដើម្បីបញ្ចូលសិទ្ធិមនុស្សទៅក្នុងយុទ្ធសាស្ត្រអន្តរជាតិ។

សិទ្ធិមនុស្សត្រូវកំណត់ថាជាកាតព្វកិច្ចរបស់រដ្ឋ ពីព្រោះថា សិទ្ធិមនុស្សនេះវាមិនទាក់ទងនឹងសម្ភារតាមរយៈការមានឥទ្ធិពលលើគ្នាទៅវិញទៅមកនៅក្នុងពលកម្មទីផ្សារ ឬសកម្មភាពមនុស្សធម៌។ ការផ្តល់អាទិភាពដល់សិទ្ធិកុមារស្តែងចេញពីការពិតដែលថាកុមារមិនអាចរង់ចាំដល់គេធំៗបានទេ។ ការរារាំងកុមារមិនឲ្យទទួលបានការអប់រំដោយប្រការណាមួយនឹងធ្វើឲ្យមានការលំបាក និងញឹកញាប់ មិនអាចដោះស្រាយបាននៅពេលក្រោយទៀតផង។ ស្តង់ដាសិទ្ធិមនុស្សសកលត្រូវតែបញ្ចូលទៅក្នុង យុទ្ធសាស្ត្រអប់រំជាតិពីព្រោះថា ការអប់រំមានឥទ្ធិពលច្រើនយ៉ាងណាស់ : នៅកន្លែងដែលសិទ្ធិអប់រំត្រូវបានគេធានាពេញលេញហើយ ការអប់រំនឹងត្រូវពង្រីកឲ្យទទួលបានសិទ្ធិផ្សេងទៀត និងសេរីភាព។ ចំណែកនៅកន្លែងសិទ្ធិទទួលការអប់រំត្រូវបានគេបដិសេធនឹងសិទ្ធិដទៃទៀតត្រូវគេរារាំងមិនឲ្យមានដែរ។ កាតព្វកិច្ចសិទ្ធិមនុស្សរដ្ឋាភិបាលផ្អែកលើគោលការដែលថាការអប់រំគឺជាទ្រព្យសម្បត្តិសាធារណៈ ហើយការរៀបចំឲ្យមានស្ថាប័នសិក្សាគឺជាសេវាសាធារណៈ។

**ការអះអាងអំពីតម្រូវការឲ្យមានការអប់រំដោយឥតបង់ថ្លៃ និងដោយកាតព្វកិច្ច**

ប្រវត្តិសាស្ត្របង្ហាញថាការអប់រំដោយកាតព្វកិច្ច និងដោយមិនគិតថ្លៃបង្ហាញពីជោគជ័យនៅក្នុងការលុបបំបាត់ពលកម្មកុមារ។ ប្រហាក់ប្រហែលគ្នានេះដែរ ការបង្កើតឱកាសសិក្សារបស់ក្មេងស្រីឲ្យដល់មធ្យមសិក្សានឹងបង្កើតអាយុរៀបការ និងមានកូនរបស់កុមារី។ ជាលទ្ធផលកុមារនៅជំនាន់ក្រោយមកទៀតងាយស្រួលទទួលការអប់រំ ពីព្រោះថា ចំនួនកុមារថយចុះ ហើយពួកគេកើតមកដោយមានឪពុកម្តាយជាអ្នកចេះដឹង។

ការអប់រំគឺជាមធ្យោបាយគន្លឹះបញ្ជាក់ពីបញ្ហាសិទ្ធិមនុស្សនានា ដូច្នេះគេត្រូវតែឯកភាពគ្នាបញ្ជ្រាបសិទ្ធិ មនុស្សនៅក្នុងប្រព័ន្ធអប់រំ។ បទពិសោធន៍អតីតកាលបង្ហាញថា ការកំណត់ការអប់រំជាយានដើម្បីរកការងារធ្វើនៅក្នុងសង្គមគឺជាការយល់ច្រឡំនៅពេលដែលរដ្ឋាភិបាលរបស់សមីប្រទេសលែងជា និយោជកសំខាន់នៅក្នុងការផ្ដល់ការងារ។ បន្ទាប់ពីបានរៀនសូត្រពីបទពិសោធន៍ទាំងនេះ គោលនយោបាយអប់រំត្រូវតែរៀបចំយ៉ាងណាឲ្យឆ្លើយតបទៅនឹងពលកម្មទីផ្សារដែលប្រែប្រួល ឥតឈប់ឈរ។ លើសពីនេះទៀត ព័ត៌មានស្ថិតិវាស់កំរិតចេះដឹងបែបបុរាណទាក់ទងនឹងលទ្ធផលនៃ ការសិក្សារបស់កម្មវិធីសាលាប៉ុណ្ណោះ វាមិនបញ្ជាក់ពីជំនាញ និងលទ្ធផលពិតប្រាកដរបស់អ្នករៀនចប់នោះទេ។ ជំនាញ និងលទ្ធភាពទាំងនេះជាអ្នកទ្រទ្រង់ការអប់រំឲ្យនៅស្ថិតស្ថេរមិនមែនការចេះចាំខ្លឹមសារមេរៀនពីសាលានោះទេ។

ការកែទម្រង់អប់រំក្លាយជាស្ដង់ដាររួមនៅក្នុងប្រទេសជាច្រើនចាប់តាំងពីចូលសហស្សវត្សថ្មីមក។ ការសម្របសម្រួលតាមនិន្នាការអន្តរជាតិ និងដំណើរការសកលភាវូបនីយកម្មជាអ្នកជំរុញឲ្យមានការកែទម្រង់ទាំងនេះ។ ប៉ុន្តែគេពុំដែលឃើញមានឯកសារបញ្ជាក់ពីគោលបំណងនៃការអប់រំបែបនេះទេ។ គេពុំឃើញមានការបែងចែក ឬកៀរគរធនធានដើម្បីសំរេចគោលដៅនេះទេ។ ពុំមានការបញ្ជាក់ច្បាស់លាស់ពីការទទួលខុសត្រូវរបស់រដ្ឋ ឬស្ថាប័នពាក់ព័ន្ធទេ។ ការកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកពាក់ព័ន្ធនិងនីតិវិធីនានាដើម្បីសំរេចគោលដៅនេះក៏មិនឃើញមានដែរ។

ជាទីបញ្ចប់ តម្រូវការបញ្ចូលការអប់រំទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍបង្កឲ្យមានឱកាសផ្សេងទៀតសំរាប់ពិភាក្សាលើបញ្ហាផ្សេងៗ ដែលបន្ទាប់មកនឹងជួយឲ្យគេរៀបចំការអប់រំតាមតម្រូវការរបស់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់។ នេះគឺជាហេតុផលយ៉ាងច្បាស់ ដែលគោលដៅការអប់រំសំរាប់ទាំងអស់គ្នា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិទាមទារឲ្យមាននៅក្នុងផែនការជាតិ។ ឯកសារនេះត្រូវបានសរសេរឡើងដើម្បីសម្រួលដល់ដំណើរការនេះដោយការសង្ខេបខ្លីៗ និងងាយស្រួលនូវបញ្ហាសិទ្ធិមនុស្សសំខាន់ៗដែលត្រូវបញ្ចូលទៅក្នុងផែនការជាតិ។

# BIBLIOGRAPHY

Commission on Human Rights - 12 Years of Human Rights Advocacy: 1998 Annual Report, Quezon City.

Commission on Human Rights - Annual report of the Special Rapporteur on the right to education, E/CN.4/2002/60.

Economic and Social Commission for Asia and the Pacific - Human Rights and Legal Status of Women in the Asian and Pacific Region, United Nations, New York, 1997.

Gender and Education for All: The Leap to Equality. EFA Global Monitoring Report2003/4, available at www.unesco.org/education/efa_report

General Assembly - Road map towards the implementation of the United Nations Millennium Declaration: Report of the Secretary-General, U.N. Doc.

General Assembly - Strengthening of the United Nations: an agenda for further change. Report of the Secretary-General, U.N. Doc.

International Labour Office - A Future without Child Labour. Global Report under the Follow-up to the ILO Declaration on Fundamental Principles and Rights at Work, International Labour Conference, 90th session (2002).

The National Commission on Human Rights Indonesia - Annual Report 2000, Jakarta, 2001.

Tomasevski, K. - A Handbook on CEDAW, the Convention on the Elimination of All Forms of Discrimination against Women, Swedish Ministry for Foreign Affairs/Sida, Stockholm, 1999, pp. 16 and 37.

Tomasevski, K. - Women, in: Eide, A. Et al. (eds.) - Economic, Social and Cultural Rights, Martinus Nijhoff Publishers, Dordrecht, 1995, pp. 275-281.

Towards an ASEAN Human Rights Mechanism: Proposals, Declarations and Related Documents, Working Group for an ASEAN Human Rights Mechanism, 1999.

1998 World Education Report UNESCO, Paris, 1999.

UNESCO Executive Board - Elements for an overall UNESCO strategy on human rights, Doc. 165 EX/10 (2002).

State of the World Population 2002, UNFPA, New York, 2003.

Wilson, D. - Minority Rights in Education, available at www.right-to-education.org

Women’s Education and Fertility Behaviour. Recent Evidence from the Demographic and Health Surveys, U.N. Doc. ST/ESA/SER.R/137, United Nations, New York, 1995.

World Bank - User Fees in Primary Education, Draft for Review, February 2002.

World Trade Organization - Negotiating proposal for education services: Communication from New Zealand, S/CSS/W/93 of 26 June 2001.

**គ្រប់គ្រងដោយ :**

លោក អេដែន ក្លេម៉ង់
អ្នកតំណាងអង្គការ UNESCO ប្រចាំនៅកម្ពុជា
លោកបណ្ឌិត សម្តោជសែនកុន ប្រសើរសេរី
អ្នកឯកទេសកម្មវិធីអប់រំ UNESCO

**បកប្រែអត្ថបទជាភាសាខ្មែរដោយ :**

បណ្ឌិត ឈិញ ស៊ីថា

**ផ្ទៀងផ្ទាត់ និងសំរួលអត្ថបទជាភាសាខ្មែរដោយ :**

លោក ខៀវ វីដ្ឋានន្ទ

**ចែកចាយដោយ UNESCO PHNOM PENH**

បកប្រែក្រៅផ្លូវការ

ការអប់រំយកសិទ្ធិមនុស្សជាមូលដ្ឋាន
សិទ្ធិមនុស្ស
ជាសាកល
តម្រូវការដ៏សាមញ្ញ